00231594

D99/3/20

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អង្គបុរេជំនុំជម្រះ**
PRE-TRIAL CHAMBER
CHAMBRE PRÉLIMINAIRE

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០១/១៨-០៧-២០០៧-អវតក-កសចស (អបជ០២)

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ប៉ែន ពេជ្រសាលី
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 13 / 10 / 2008
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fay

**កាលបរិច្ឆេទ:** ១៣ តុលា ២០០៨

---

## សាធារណៈ:

## សេចក្តីជូនដំណឹងអំពី ការដកខ្លួនរបស់លោក ចៅក្រម នៃយ ថុល

---

**ការិយាល័យសហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT
យ៉េត ចរិយា
William SMITH
ពេជ្រ សម្បត្តិ
Alex BATES

ឯកសារបានចំលងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 13 / 10 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fay

**ជនត្រូវចោទ**
កាំង ហ្កេកអ៊ាវ ហៅ "ឌុច"

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
គង់ ពិសី
ហុង គឹមសួន
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANNONE

**សហមេធាវីការពារក្តី**
ការ សាវុត្ថ
François ROUX

១. **អង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** (“**អវតក**”) កត់សម្គាល់ឃើញថា ខ្លួនបានទទួលលិខិតមួយច្បាប់ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៨ ពីលោកចៅក្រម **ន៉យ ថុល** ដោយនៅក្នុងលិខិតនោះ បានជម្រាបលោកប្រធានអង្គបុរេជំនុំជម្រះ អំពី “សំណើសុំដកខ្លួនចេញពីសំណុំរឿងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា នឹងដីកាបញ្ជូនរឿង កាំង ហ្កេកអ៊ាវ ហៅ “ឌុច” ទៅជំនុំជម្រះ (សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អបជ០២))” (“លិខិត”)។

២. នៅក្នុងលិខិតនេះ លោកចៅក្រម **ន៉យ ថុល** ជម្រាបលោកប្រធានថា គាត់បានសម្រេចចិត្តដកខ្លួនពីការជំនុំជម្រះក្នុងសំណុំរឿងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា នឹងដីកាបញ្ជូនរឿង **កាំង ហ្កេកអ៊ាវ** ហៅ “**ឌុច**” ទៅជំនុំជម្រះ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨ ដែលបណ្តឹងឧទ្ធរណ៍នេះបានដាក់នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨ (“បណ្តឹងឧទ្ធរណ៍”)។

៣. វិធាន ៣៤(១) នៃវិធានផ្ទៃក្នុង ចែងថា:

> ចៅក្រមអាចដកខ្លួនឯងចេញពីករណីណាមួយ ដែលចៅក្រមរូបនោះមាន ឬ ធ្លាប់មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬ ហិរញ្ញវត្ថុ ឬ មានការពាក់ព័ន្ធ ដែលអាចធ្វើឲ្យប៉ះពាល់យ៉ាងពិតប្រាកដដល់ភាពអនាគតិរបស់ចៅក្រមរូបនោះ ឬ អាចបង្កើតឲ្យមានភាពលំអៀង។ សហចៅក្រមស៊ើបអង្កេតណាម្នាក់ដែលដកខ្លួនចេញពីការងារ ត្រូវផ្តល់ព័ត៌មានទៅដល់ប្រធានអង្គបុរេជំនុំជម្រះ។ បើជាចៅក្រមជម្រះក្តី ត្រូវផ្តល់ព័ត៌មានទៅដល់អង្គជំនុំជម្រះដែលខ្លួនស្ថិតនៅ។ ចៅក្រមដែលកំពុងមានបញ្ហាត្រូវឈប់ចូលរួមជាបន្ទាន់ ក្នុងកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះ។

៤. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញបន្ថែមទៀតចំពោះ ជំពូកទី៤ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។

៥. ដោយសារលោកចៅក្រម **ន៉យ ថុល** បានដកខ្លួនចេញពីការជំនុំជម្រះនៅក្នុងរឿងក្តីនេះ លោកចៅក្រមត្រូវបានជំនួសជាបន្ទាន់ ដោយលោកចៅក្រមបម្រុង **ប៉ែន ពេជ្រសាលី** នៅក្នុងអំឡុងពេលដំណើរការនីតិវិធីក្នុងសំណុំរឿងបណ្តឹងឧទ្ធរណ៍នេះ។

៦. នៅក្នុងសមាសភាពនៃក្រុមប្រឹក្សាជំនុំជម្រះថ្មី អង្គបុរេជំនុំជម្រះបញ្ជាក់ថា កិច្ចនីតិវិធីទាំងអស់ចំពោះសំណុំរឿងបណ្តឹងឧទ្ធរណ៍នេះ ត្រូវបានធ្វើចំណាត់ការ មុនពេលការដកខ្លួនរបស់លោកចៅក្រម **ន៉យ ថុល**។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះជូនដំណឹង**:

ភាគី និងសាធារណៈជន ថា លោកចៅក្រម **ន៉យ ថុល** ត្រូវបានជំនួសដោយលោកចៅក្រមបម្រុង **ប៉ែន ពេជ្រសាលី** នៅក្នុងអំឡុងពេលដំណើរការនីតិវិធីក្នុងសំណុំរឿងបណ្តឹងឧទ្ធរណ៍។ ៕

ភ្នំពេញ ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន**

00231596

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

D99/3/20

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

**គោរពជូន**

**លោកចៅក្រម ប្រាក់ គឹមសាន**

**ប្រធានអង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញ**

**កម្មវត្ថុ:** សំណើសុំដកខ្លួនចេញពីសំណុំរឿង បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា នឹងដីកាបញ្ជូនរឿង កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ទៅជំនុំជម្រះ (សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អបជ០២)

**យោង:** លិខិតចុះថ្ងៃទី៦ វិច្ឆិកា ២០០៧។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកប្រធានមេត្តាជ្រាបថា ខ្ញុំបានសម្រេចចិត្តដកខ្លួនពីការជំនុំជម្រះក្នុងសំណុំរឿងខាងលើ។

អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាអនុញ្ញាតតាមការគួរ។

សូមលោកប្រធាន មេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះអំពីខ្ញុំ។

ភ្នំពេញ ថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០០៨

**ចៅក្រមអង្គបុរេជំនុំជម្រះ**

**ន័យ ថុល**

បានឃើញ និង ឯកភាព

09-10-08

PRE-TRIAL CHAMBER ECCC

**ប្រាក់ គឹមសាន**

00231597

D99/3/20

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

**<u>ជម្រាបជូន</u>**
**លោកប្រធានអង្គបុរេជំនុំជម្រះ**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**<u>កម្មវត្ថុ:</u>** សំណើសុំដកខ្លួនចេញពីការជំនុំជម្រះរឿងព្រហ្មទណ្ឌលេខ ០២/១៤-០៨-២០០៦-អវតក/អបជ ទាក់ទង នឹងការឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ។

**<u>យោង:</u>** វិធាន ៣៤ នៃវិធានផ្ទៃក្នុងសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោកប្រធានមេត្តាជ្រាបថា: ដោយសារខ្ញុំមានតួនាទីជាប្រធានតុលាការយោធា ហើយជនត្រូវចោទ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ធ្លាប់បានឃុំខ្លួនជាបណ្តោះអាសន្ននៅតុលាការយោធា ដូច្នេះខ្ញុំសូមដកខ្លួនចេញពីការជំនុំជម្រះក្នុងរឿងព្រហ្មទណ្ឌខាងលើ។

អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាអនុញ្ញាតតាមការគួរ។

សូមលោកប្រធានមេត្តាទទួលការគោរពរាប់អានដ៏ស្មោះអំពីខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី..០៦....ខែ..វិច្ឆិកា....ឆ្នាំ..២០០៧.

**ចៅក្រមអង្គបុរេជំនុំជម្រះ**

**ង៉ុយ ធុល**